# មន្ទីរកសិកម្មខេត្តកណ្តាល

# ដង្កូវបំពង់កាត់ស្លឹក




អាស័យដ្ឋានទំនាក់ទំនងៈ ផ្លូវលេខ ១០៣ (តាខ្មៅ)

ទំនាក់ទំនងទូរស័ព្ទ (០២៣ ៩៨៣ ៤៦១)

(០១២ ៨២៤ ៤២៥)



ឧបត្ថម្ភដោយៈ អង្គការវីវីអូប៊ី VVOB

ឆ្នាំ ២០១០


# ដង្កូវបំពង់កាត់ស្លឹក

## ១-លក្ខណៈទូទៅ

ដង្កូវបំពង់កាត់ស្លឹកជាប្រភេទសត្វចង្រៃ ម្យ៉ាងដែលបំផ្លាញដំណាំស្រូវចាប់ពីដំណាក់កាលសំណាបរហូតដល់ដំណាក់កាលស្រូវបែកគុម្ព ជាពិសេសពេលស្រូវនៅខ្ចី ។ វាជាសត្វល្អិតអាចរស់នៅបានទាំងក្នុងទឹក និងលើគោក។ ក្នុងវ័យជាដង្កូវវាស៊ីបំផ្លាញស្លឹកស្រូវខ្ចីរួចកាត់ស្លឹកស្រូវមូរខ្លួនវាជាបំពង់ទំលាក់ចុះមកក្រោមរួចបណ្តែតខ្លួនលើផ្ទៃទឹក។ ដង្កូវប្រភេទនេះវារស់នៅក្នុងបំពង់ស្លឹកស្រូវ ហើយបណ្តែតខ្លួនលើផ្ទៃទឹកនៅពេល ថ្ងៃ ពេលយប់វាតោងឡើងដើមស្រូវទាំងបំពង់ដើម្បីស៊ីស្លឹកស្រូវជាអាហារ។

ដង្កូវប្រភេទនេះច្រើនកើតនៅលើដីស្រែដែលពុំបានរៀបចំស្មើល្អ និងលើស្រែដែលមានទឹកដក់ជាប្រចាំ។ មេអំបៅពេលថ្ងៃលាក់ខ្លួនក្នុងគុម្ពស្មៅ និង ចេញទៅពងពេលយប់ដែលអាចមានចំនួន ៥០ពង ។



## ២-លក្ខណៈរូប

-ពង មានពណ៌សព្រលែត/ពណ៌លឿងខ្ចី ឬពណ៌សដូចទឹកសន្សើម (ពងរបស់វាមានរាងមូលដូចថាស មានទំហំមិនស្មើគ្នាតំរៀបជាជួរខាងក្រោមផ្ទៃស្លឹក ជិតញាស់ប្រែជាពណ៌លឿងចាស់)។

-ដង្កូវ មានពណ៌លឿងថ្លា ឬ ខៀវព្រលែតពេលវាស៊ីចំណីអាហាររួច។

-ដឹកឌឿ មានពណ៌សព្រលែត ឬ ពណ៌ទឹកដោះគោ (ពណ៌ត្នោត)។

-មេអំបៅ មានពណ៌ដូចទឹកប្រាក់ (សស្លេករលេចដោយដុំ ឬឆ្នូតពណ៌ត្នោតខ្ចី) ហើយមានចំណុចអុចៗនៅលើស្លាប។



## ៣-វដ្តជីវិត

-មេអំបៅ មានរយៈពេល ៧ថ្ងៃ (ពងនៅលើស្លឹកស្រូវដែលធ្លាក់សំយ៉ាកក្បែរផ្ទៃទឹក )

-ពង មានរយៈពេល ៣-៥ថ្ងៃ។

-ដង្កូវ មានរយៈពេល ២០ថ្ងៃ (ដឹកឌឿតោងជាប់គុម្ពស្រូវ ក្បែរផ្ទៃទឹក )

-ដឹកឌឿ មានរយៈពេល ៧ថ្ងៃ




## ៤-លក្ខណៈបំផ្លាញ

-ចាប់ពីសំណាប រហូតដល់ស្រូវបែកគុម្ព ពិសេសពេលស្រូវនៅខ្ចី (វាបំផ្លាញលើថ្នាលសំណាបដែលមានទឹក និង សន្ទូងទើបលាស់ថ្មី)

-ស៊ីបកជាលិកាពណ៌បៃតង ដោយបន្សល់ទុកនៅភ្នាសស្តើងរាងជាថ្នាក់ៗ ដូចកាំជណ្តើរ (ដង្កូវស៊ីស្រទាប់ក្លូរ៉ូហ្វីលទុកតែស្រទាប់ជាលិកា នៅលើផ្ទៃស្លឹកដូចក្រដាស ឬស្បៃមុង ស្លឹកដែលត្រូវវាបំផ្លាញមានស្នាមកាត់ដូចមុខកន្ត្រៃ)។

-កាត់ចុងស្លឹកស្រូវធ្វើជាបំពង់ បណ្តែតលើផ្ទៃទឹកនៅពេលថ្ងៃ បំផ្លាញស្លឹកស្រូវនៅពេលយប់។



*ការបំផ្លាញរបស់ដង្កូវបំពង់កាត់ស្លឹក មានរយៈពេលពី ២០ថ្ងៃ*

## ៥-វិធានការការពារ និងកំចាត់

- សំអាតស្រែជាប្រចាំ
- ធ្វើថ្នាលសំណាបគោក អាចជៀសវាងបានពីការបំផ្លាញ
- ធ្វើទីថ្នាលសំណាបឱ្យបានរាបស្មើល្អ និងឆ្ងាយពីវាលស្មៅដែលជាជំរករបស់វា ។
- ពន្លិចទឹកក្នុងស្រែ ឬ ថ្នាលសំណាប ហើយកៀរបំពង់ដង្កូវចោល ឬ យកទៅធ្វើចំណីទា។
- បង្ហូរទឹកចេញពីស្រែរយៈពេល ២-៣ថ្ងៃ (ដោយសារដង្កូវមិនអាចដកដង្ហើមបាននៅលើគោក ដូច្នេះវានឹងស្លាប់)
- ថែរក្សាសត្វមានប្រយោជន៍ដូចជា: ពពួកឪម៉ាល់ កន្ទុំរុយពីងពាង ស្រីងទឹក ខ្មូតដី អណ្តើកមាស ...។ល ។

វិធានការដ៏មានប្រសិទ្ធភាពបំផុតគឺ ការបង្ហូរទឹកចេញឱ្យអស់ពីស្រែ។ ដោយសារដង្កូវបំពង់កាត់ស្លឹកជាប្រភេទសត្វល្អិតដែលមានជីវិតពាក់កណ្តាលលើកគោក និង ពាក់កណ្តាលក្នុងទឹក ដូច្នេះនៅពេលគ្មានទឹកក្នុងស្រែ ដង្កូវមានការលំបាកក្នុងការដកដង្ហើមស្រូបយកអុកស៊ីសែនពីក្នុងទឹក តាមរយៈរោមញ៉ូរនៅជុំវិញខ្លួនរបស់វា បន្ទាប់មកវានឹងស្លាប់។



*ការប្រើប្រាស់ថ្នាំកសិកម្មជាជំរើសចុងក្រោយបង្អស់ក្នុងការកំចាត់ដង្កូវបំពង់កាត់ស្លឹក*

(ដើម្បីសុវត្ថិភាព និងជាប្រយោជន៍របស់លោកអ្នក សូមប្រើប្រាស់តែថ្នាំកសិកម្មដែលបានចុះបញ្ជិកា និងអនុវត្តអោយបានត្រឹមត្រូវតាមការណែនាំក្នុងស្លាកសញ្ញា) ។